ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ ០៣៩/២៣ អអរ

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី «ភាពជោគជ័យរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តក្រចេះ»

រសៀលថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តក្រចេះ»** ដែលមានវាគ្មិនចូលរួមគឺៈ

- **ឯកឧត្តម វ៉ា ថន អភិបាល នៃគណៈអភិបាលខេត្តក្រចេះ**
- **មន្ទីរជំនាញជុំវិញខេត្តក្រចេះ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. សេចក្តីផ្តើម

ខេត្តក្រចេះ ស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ដែលចែកចេញជា ១ក្រុង ៥សង្កាត់ ៦ស្រុក និង៤៣ឃុំ ស្មើនឹង ៣២៧ភូមិ ដែលមានប្រជាជនសរុប ៤៣៨.៦៤១នាក់ ស្រី ២២១.២៧៤នាក់ ស្មើនឹង ១០០.៦៧៧គ្រួសារ ក្នុងនោះ ប្រជាពលរដ្ឋជាកសិករចំនួន ៧៩,៦% មន្ត្រីរាជការ ៣,២% ឧស្សាហករ-សិប្បករ ០,៤% ពាណិជ្ជករ ៦,៨% និងជាសេវាករ ១០%។ នៅក្នុងឆ្នាំ២០២១ សេដ្ឋកិច្ច

ខេត្តក្រចេះ មានទំហំ ២,២៦៥,៣៩៤.៩លានរៀល ស្មើនឹង ២,០៥% នៃសេដ្ឋកិច្ចជាតិ ដែលចំណូលប្រជាពលរដ្ឋ០១នាក់(GDP) ស្មើនឹង ១.៣២៥ដុល្លារអាមេរិក។

## II. សមិទ្ធផលសំខាន់ៗ

ដោយអនុវត្តស្របតាមកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណទាំង ៤ដំណាក់កាល ផែនការអភិវឌ្ឍរយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល អនុម័តដោយក្រុមប្រឹក្សាខេត្ត គឺជាត្រីវិស័យសម្រាប់ឱ្យរដ្ឋបាលខេត្តសម្រេចបាននូវសមិទ្ធផលជាច្រើនរួមមាន៖ ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ប្រព័ន្ធធារាសាស្ត្រ ការកែលម្អសោភ័ណភាពបរិស្ថាន និងការផ្តល់សេវាសាធារណៈ។ សមិទ្ធផលសំខាន់ៗ ដែលខេត្តសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ខេត្តបានបន្តអនុវត្តនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងជនងាយរងគ្រោះបាន ២៨.២៥៥គ្រួសារ ចំណាយថវិកាសរុប ១៥០.៣៧០.៦៨០.០០០រៀល កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ បានចំនួន ១០.៤៦៤នាក់ ចំណាយថវិកាសរុប ៤.២៥៧.៦៤០.០០០រៀល និងការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដោយគ្រោះទឹកជំនន់មានចំនួន ៨.៦៧០គ្រួសារ ប្រាក់ឧបត្ថម្ភសរុប ១.៣៤៩.៤០៨.០០០រៀល និងសម្ភាជអតីតផរណាមានចំនួន ៧.០៩១គ្រួសារ ទទួលប្រាក់ឧបត្ថម្ភសរុប ៩៨៣.២១៦.៣០០រៀល កម្មវិធីទាំងអស់នេះបានរួមចំណែកសម្រួលជីវភាពរបស់គ្រួសារក្រីក្រ ឱ្យរួចផុតពីការធ្លាក់ចូលទៅក្នុងបញ្ហាអសន្តិសុខស្បៀង បំណុល ការលក់ទ្រព្យសកម្មរបស់គ្រួសារ និងបានសម្រួលបន្ទុកចំណាយរបស់គ្រួសារ។ បន្ថែមពីនេះ ខេត្តក៏បានផ្តល់ដីជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារចូលនិវត្តន៍ ៣៨៨ខ្នងផ្ទះ និងផ្តល់ដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រខ្វះដីលំនៅឋាន និងដីបង្កបង្កើនបានចំនួន ៥.៣២៤គ្រួសារផងដែរ។
- **វិស័យកសិកម្ម៖** ដោយប្រជាពលរដ្ឋប្រមាណជិត ៨០% ជាកសិករ ដូចនេះ សេដ្ឋកិច្ចខេត្ត ពឹងផ្អែកលើវិស័យកសិកម្មនេះជាចម្បង។ ក្នុងឆ្នាំ២០២២ ដំណាំស្រូវអនុវត្តបានចំនួន ៥៤.៦៨២ហិកតា ទទួលបានបរិមាណផលស្រូវសរុប ១៧៨.៨៣៨តោន និងអនុវត្តការដាំដុះដំណាំរួមផ្សំសរុបចំនួន ១០១.១៩៨ហិកតា ក្នុងនោះដំណាំសាកវប្បកម្មមាន៖ដំណាំបន្លែគ្រប់ប្រភេទ,ពោតស, ដំឡូងគរ,ដំឡូងជ្វា,និងប៉ិះគក់សរុបចំនួន ៩.៥១៩ហិកតា ស្មើនឹង ១០៥,៧៦% ទទួលបានបរិមាណផលចំនួន ៧០.០៩៨តោន និងដំណាំឧស្សាហកម្មរយៈពេលខ្លីមាន៖ ពោតក្រហម សណ្តែកបាយ សណ្តែកដី សណ្តែកសៀង ល្ង ថ្នាំជក់ និងអំពៅសរុបចំនួន ៩១.៦៧៩ហិកតា

ស្មើនឹង ១០៥,១៣% ទទួលបានបរិមាណផលចំនួន ១.៥៣១.៧០៤តោន។ ចំពោះដំណាំកសិឧស្សាហកម្មវិញសម្រេចបាន កៅស៊ូសរុបចំនួន ៨៦.៣៧៤ហិកតា ដំឡូងមីចំនួន ៧៣.៩៨៩ហិកតា ស្វាយចន្ទីចំនួន ៦៤.៩១៧ហិកតា ចេកអំបូងលឿងចំនួន ៣.៤៥៥ហិកតា អំពៅចំនួន ៦០០០ហិកតា ម៉ៃសាក់ចំនួន ១.៦៥១ហិកតា និងឈើហូបផ្លែចំនួន ៦៨១ហិកតា។ ខេត្តមានប្រព័ន្ធស្រោចស្រពសម្រាប់ផ្គត់ផ្គង់ទូទាំងខេត្ត ៧៤ប្រព័ន្ធ ទំនប់ប្រវែង ៧៤.២៦៥ម៉ែត្រ ប្រឡាយមេប្រវែង ១៣៦.០៨២ម៉ែត្រ ប្រឡាយរងប្រវែង ៦១.១៣៦ម៉ែត្រ សំណង់បង្ហៀរ ៥១កន្លែង ទ្វារទឹក ៧៨កន្លែង និងលូ ៣៥២កន្លែង។

- **ការងារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** រដ្ឋបាលខេត្ត បាននឹងកំពុងបន្តកសាង ពង្រីក ជួសជុលផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវលំជនបទ រួមទាំងស្ពានថ្មធំៗ ដោយធានាបាននូវការធ្វើដំណើរកាន់តែមានភាពងាយស្រួលទៅគ្រប់បណ្ដាក្រុង ស្រុក ឃុំ សង្កាត់ និងភូមិ ប្រទាក់ក្រឡាគ្នាដល់ជនបទដាច់ស្រយាល បម្រើសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋក្នុងការទំនាក់ទំនង ការធ្វើដំណើរ និងការដឹកជញ្ជូនកសិផល និងផលិតផលមកកាន់ទីផ្សារបានយ៉ាងឆាប់រហ័ស។ បច្ចុប្បន្ននេះ ទូទាំងខេត្តមានហេដ្ឋារចនាសម្ព័ន្ធរូបវន្តសរុបប្រវែង ១.១៩០,៤២គីឡូម៉ែត្រ ក្នុងនោះផ្លូវក្រាលកៅស៊ូគ្រប់ប្រភេទប្រវែង ៣៩៩,១១គីឡូម៉ែត្រ ផ្លូវបេតុងប្រវែង ៣,១១គីឡូម៉ែត្រ ក្រាលក្រួសក្រហមប្រវែង ៧៨៨,២០គីឡូម៉ែត្រ ស្ពានចំនួន ១៣៨កន្លែង ប្រវែង ៤.៦៦៩,៤ម៉ែត្រ លូគ្រប់ប្រភេទ ១.២៥៦កន្លែង ប្រវែង ៥១.០៣២ម៉ែត្រ។
- **ការងារអភិវឌ្ឍន៍ជនបទ៖** ខេត្តបានខិតខំជំរុញការងារអភិវឌ្ឍន៍ជនបទនេះ ដោយផ្ដោតទៅលើការអភិវឌ្ឍផ្លូវលំ ទឹកស្អាត និងការងារអនាម័យជនបទ ដោយសម្រេចបានថែទាំផ្លូវលំជាប្រចាំចំនួន ៣១ខ្សែ ប្រវែង ៤៨០.៩០គីឡូម៉ែត្រ ផ្លូវថែទាំលក្ខណៈខួបបានចំនួន ១០ខ្សែ ប្រវែង ១០៤.៥៥គីឡូម៉ែត្រ ផ្លូវជួសជុលបន្ទាន់បានចំនួន ០៨កំណាត់ខ្សែផ្លូវ ប្រវែង ១៩.១០គីឡូម៉ែត្រ ជួសជុលស្ពានឈើបានចំនួន ១៧កន្លែង ប្រវែង ៣៤៩ម៉ែត្រ ជួសជុលស្ពានបេតុងបានចំនួន ២៧កន្លែង ប្រវែង ៧៥១.៥០ម៉ែត្រ ព្រមទាំងសម្រេចបានការស្ថាបនាផ្លូវក្រាលកៅស៊ូជនបទប្រភេទ DBST ចំនួន ៤ខ្សែ ប្រវែង ៨៤គីឡូម៉ែត្រ។ ជាមួយគ្នានេះ ខេត្តសម្រេចបាននូវការផ្គត់ផ្គង់ទឹកស្អាត ៨៣% និងអត្រាគ្របដណ្ដប់ផ្នែកបង្គន់អនាម័យទូទាំងខេត្តមានប្រមាណ ៦៣%។
- **វិស័យទេសចរណ៍៖** វិស័យទេសចរណ៍នេះ ក៏បានចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈការបង្កើតការងារជូនប្រជាពលរដ្ឋនៅមូលដ្ឋាន និងចំណូលផ្ទាល់ពីភ្ញៀវទេសចរ។

ទូទាំងខេត្តមានរមណីយដ្ឋានទេសចរណ៍ជាច្រើនកន្លែង ជាពិសេសគឺធនធានសត្វផ្សោតទឹកសាប ដែលជាគោលដៅទេសចរណ៍ដ៏សំខាន់ ជាក់ស្តែងក្នុងឆ្នាំ២០២២ ខេត្តទទួលបានភ្ញៀវទេសចរសរុប ៣៦៣.៩៨២នាក់ ក្នុងនោះភ្ញៀវទេសចរអន្តរជាតិចំនួន ៧.០៦៥នាក់ និងភ្ញៀវទេសចរជាតិ ៣៥៦.៩១៧នាក់។

- **ការធ្វើវេទិកាសាធារណៈ៖** ខេត្តបានអនុវត្តការចុះធ្វើវេទិកាសាធារណៈ នៅតាមមូលដ្ឋានឃុំសង្កាត់ផ្ទាល់ ដើម្បីស្វែងយល់ពីតម្រូវការ និងសំណូមពររបស់ប្រជាពលរដ្ឋផ្ទាល់ ជាក់ស្តែង ក្នុងឆ្នាំ២០២២ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្ត បានរៀបចំវេទិកាសាធារណៈចំនួន ១៥ លើក ទទួលបានសំណើ និងសំណូមពរចំនួន ៧៧ករណី ដោះស្រាយបានចំនួន ៤៥ករណី និងកំពុងសិក្សាដោះស្រាយចំនួន ៣១ករណី។

## III. សម្គាល់

រដ្ឋបាលខេត្តក្រចេះបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការងារការពារ និងអភិរក្សសត្វផ្សោតទន្លេមេគង្គ ដែលជាធនធានដ៏កម្រ និងជាគោលដៅទេសចរណ៍ធំមួយរបស់ខេត្ត ដោយឆ្មាំទន្លេប្រចាំខេត្ត និងសមាជិកឆ្មាំទន្លេតាមបណ្តាលប៉ុស្តិ៍ប្រចាំការទាំង១១ បានរៀបចំផែនការសកម្មភាពដើម្បីសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលស្រុក អធិការដ្ឋានរដ្ឋបាលជលផលមេគង្គរដ្ឋបាលជលផលក្រចេះ និងកម្លាំងនគរបាលនៃស្នងការដ្ឋាននគរបាលខេត្ត ចុះល្បាតប្រចាំការ និងប្តូរវេនត្រួតពិនិត្យ បង្ក្រាបបទល្មើសនេសាទតាមដងទន្លេមេគង្គក្នុងតំបន់គ្រប់គ្រង ការពារអភិរក្សសត្វផ្សោត និងជីវចម្រុះជលផល ចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសនៅដែនអភិរក្សជាប្រចាំ៕

ថ្ងៃអង្គារ ១០កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣